# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី ១៥

LECTURE 15

## ទំនាក់ទំនងកុងស៊ុល

CONSULAR RELATIONS

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្តីផ្តើម
- ផ្នែកទី២ ការបង្កើត និងផ្តាច់ទំនាក់ទំនងកុងស៊ុល
    - សញ្ញាណទូទៅ
    - បុគ្គលិកកុងស៊ុល
    - តួនាទីរបស់កុងស៊ុល
- ផ្នែកទី៣ អភ័យឯកសិទ្ធិកុងស៊ុល
    - សញ្ញាណទូទៅ
    - ខ្លឹមសារអភ័យឯកសិទ្ធីកុងស៊ុល

# កម្មវត្ថុនៃមេរៀន

នៅក្នុងមេរៀនស្តីពីទំនាក់ទំនងកុងស៊ុល មានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពី៖

- សារៈសំខាន់នៃទំនាក់ទំនងកុងស៊ុល
- សមត្ថកិច្ចរបស់រដ្ឋចំពោះភ្នាក់ងារកុងស៊ុល
- កាតព្វកិច្ចរបស់ភ្នាក់ងារកុងស៊ុចំពោះរដ្ឋម្ចាស់ផ្ទះ
- មូលហេតុដែលនាំឲ្យមានការផ្តាច់ទំនាក់ទំនងកុងស៊ុល

# ផ្នែកទី១ សេចក្ដីផ្ដើម

នៅក្នុងមេរៀនទី១៤ យើងបានសិក្សារួចហើយពីទំនាក់ទំនងការទូត ចំណែកមេរៀនទី១៥នេះ យើងនឹងធ្វើការសិក្សាពីមធ្យោបាយនៃការធ្វើទំនាក់ទំនងមួយទៀតរបស់រដ្ឋ គឺទំនាក់ទំនងកុងស៊ុល។ ទំនាក់ទំនងកុងស៊ុលក៏មានប្រវត្តិយូរលង់ណាស់មកហើយដែរ។

# ផ្នែកទី១ សេចក្ដីផ្ដើម

អ្នកសិក្សាពិតជាបានដឹងហើយថា ការដំណើរការ និងការប្រព្រឹត្តិទៅរបស់រដ្ឋ គឺមិនអាចខ្វះបាននូវការធ្វើទំនាក់ទំនងគ្នាទៅវិញទៅមក ក្នុងទិសដៅបង្កើតកិច្ចសហប្រតិបត្តការទៅតាមទស្សនវិស័យនយោបាយរបស់រដ្ឋនីមួយៗ ដោយឈរលើគោលការណ៍នៃការគោរពអធិបតេយ្យរដ្ឋ។

# ផ្នែកទី១ សេចក្ដីផ្ដើម

ទំនាក់ទំនងកុងស៊ុល ត្រូវបានបង្កើតឡើងនៅសតវត្សទី១៣ ដែលទំនាក់ទំនងនេះ គឺមានការជាប់ទាក់ទងយ៉ាងជិតស្និត ទៅនិងសកម្មភាព នៃការធ្វើពាណិជ្ជកម្មអន្តរជាតិ ក្នុងក្រមខ័ណ្ឌរដ្ឋ និងរដ្ឋ ជាពិសេសពាក់ព័ន្ធសកម្មភាពរបស់រដ្ឋក្នុងការសម្របសម្រួលកិច្ចការងាររដ្ឋបាល។

# ផ្នែកទី១ សេចក្ដីផ្ដើម

យើងគួរកត់សម្គាល់ផងដែរថា ទោះជាទំនាក់ទំនងកុងស៊ុលមានវ័យចំណាស់យ៉ាងណាក៏ដោយ ក៏គេសង្កេតឃើញថាទើបតែនៅពាក់កណ្ដាលនៃសតវត្សទី២០ តែប៉ុណ្ណោះ ដែលបទដ្ឋានដែលទាក់ទៅនិងការធ្វើសកម្មភាពទំនាក់ទំនងនេះត្រូវបានចងក្រងឡើង។

# ផ្នែកទី១ សេចក្តីផ្តើម

អនុសញ្ញាអន្តរជាតិស្តីពីទំនាក់ទំណាងកុងស៊ុល ទើបត្រូវបាន អនុម័តឡើងដោយគណៈកម្មកាច្បាប់អន្តរជាតិរបស់ អង្គការ សហប្រជាជាតិ នាថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៦៣ នៅទីក្រុងវីយែនប្រទេសអូទ្រីស ។ ហើយអនុសញ្ញាអន្តរជាតិនេះ វាបានចូលជាធរមាន នៅខែមិនា ឆ្នាំ១៩៦៧។

# ផ្នែកទី១ សេចក្តីផ្តើម

ប្រសិនបើយើងធ្វើការប្រៀបធៀបទំនាក់ទំនងកុងស៊ុល និងទំនាក់ទំនងការទូត មើលក្នុងទិដ្ឋភាពទូទៅហាក់បីដូចគ្នាទាំងស្រុង។ ប៉ុន្តែប្រសិនបើយើងធ្វើការសិក្សាឲ្យបានស៊ីជម្រៅ គឺទំនាក់ទំនងទាំងពីរនេះ ពុំមានលក្ខណៈដូចគ្នាងទាំងស្រុងនោះទេ។

# ផ្នែកទី១ សេចក្តីផ្តើម

ប្រសិនបើយើងនិយាយពីទំនាក់ទំនងការទូត គឺវាមានចរិកលក្ខណៈជានយោបាយច្រើនជាង ជាពិសេសវាអាចនឹងត្រូវបង្កើតឲ្យមានទំនាក់ទំនងកម្រិតការទូតបាន ទាល់តែទំនាក់ទំនងនយោបាយរវាងរដ្ឋទាំងនោះ មានលក្ខខណ្ឌល្អប្រសើរ មានន័យថា មានទំនាក់ទំនងនយោបាយល្អ។

# ផ្នែកទី១ សេចក្តីផ្តើម

ប្រសិនបើយើងក្រឡេងមកមើល ទំនាក់ទំនងក្នុងកម្រិតកុងស៊ុលវិញ គឺមិនសូវផ្តល់លក្ខណៈសំខាន់ទៅលើផ្នែកនយោបាយនោះឡើយ។ ទំនាក់ទំនងកម្រិតកុងស៊ុលបានឲ្យតម្លៃសំខាន់ទៅលើសកម្មភាពផ្នែករដ្ឋបាល ពាណិជ្ជកម្ម និងការពារប្រជាពលរដ្ឋរបស់ខ្លួនក្នុងទឹកដីនៃរដ្ឋម្ចាស់ផ្ទះ។

# ផ្នែកទី២ ការបង្កើត និងផ្តាច់ទំនាក់ទំនងកុងស៊ុល

- សញ្ញាណទូទៅ

មិនខុសពីការភ្ជាប់ទំនាក់ទំនងការទូតនោះទេ ការបង្កើតទំនាក់ទនងកុងស៊ុល គឺត្រូវតែស្ថិននៅក្រោមវិធាននៃការយល់ព្រមរវាងរដ្ឋ និងរដ្ឋទៅវិញទៅមក។ ទន្ទឹមនិងគ្នានេះផងដែរ ការបង្កើតនូវទំនាក់ទំនងនេះគឺធ្វើឡើងដោយឆន្ទៈឯកភាជ្យ។

# ផ្នែកទី២ ការបង្កើត និងផ្តាច់ទំនាក់ទំនងក្នុងស៊ុល

• សញ្ញាណទូទៅ

សូមចង់ចាំថា ការបង្កើតទំនាក់ទំនងក្នុងស៊ុល គឺវាមិនអាស្រ័យទៅនិងអាត្ថិភាព នៃទំនាក់ទំនងការទូតនោះឡើយ ការបបង្កើត ឬការបញ្ចប់ទំនាក់ទំនងក្នុងស៊ុល អាចមានលក្ខណៈឯករាជ្យពីទំនាក់ទំនងការទូត។

# ផ្នែកទី២ ការបង្កើត និងផ្ដាច់ទំនាក់ទំនងកុងស៊ុល

- សញ្ញាណទូទៅ

ជាមួយនិងគ្នានេះផងដែរ ការផ្ដាច់ទំនាក់ទំនងការទូត គឺវាមិនមែនសុទ្ធតែនាំឲ្យមានការផ្ដាច់ទំនាក់ទំនងកុងស៊ុលនោះទេ។ ពេលខ្លះទំនាក់ទំនងការទូតត្រូវបានកាត់ផ្ដាច់ ប៉ុន្តែផ្ទុយទៅវិញ ទំនាក់នងកុងស៊ុលនៅតែបន្តរជាធម្មតា។

# ផ្នែកទី២ ការបង្កើត និងផ្តាច់ទំនាក់ទំនងកុងស៊ុល

- សញ្ញាណទូទៅ

តើមកពីមូលហេតុអ្វី បានជាមានការផ្តាច់ទំនាក់ទំនងការទូត តែវាមិននាំឲ្យមានការផ្តាច់ទំនាក់ទំនងកុងស៊ុល? ចម្លើយទៅនិងសំនួរនេះ ក៏ព្រោះតែទំនាក់ទំនងការទូត គឺមានចរិកលក្ខណៈនយោបាយជាងទំនាក់ទំនងកុងស៊ុល។

# ផ្នែកទី២ ការបង្កើត និងផ្ដាច់ទំនាក់ទំនងក្នុងស៊ុល

- សញ្ញាណទូទៅ

ចំណុចពិសេសមួយទៀត ដែលយើងគួរធ្វើការកត់សម្គាល់ផងដែរនោះគឺ ទីតាំងរបស់ស្ថានកុងស៊ុល ដែលជាទូទៅគេតែនិយមហៅថា មណ្ឌលកុងស៊ុលនោះ វាអាចមានច្រើនកន្លែងអាស្រ័យទៅតាមការចាំបាច់របស់រដ្ឋដាក់កុងស៊ុល។

# ផ្នែកទី២ ការបង្កើត និងផ្ដាច់ទំនាក់ទំនងកុងស៊ុល

- សញ្ញាណទូទៅ

ការបង្កើតឲ្យមានស្ថានកុងស៊ុល ឬ មណ្ឌលកុងស៊ុលច្រើនកន្លែងរបស់រដ្ឋដាក់កុងស៊ុល នៅលើទឹកដីនៃរដ្ឋម្ចាស់ផ្ទះនេះ គឺដាច់ខាតត្រូវមានការព្រមព្រៀងគ្នា រវាងរដ្ឋដាក់កុងស៊ុល និងរដ្ឋម្ចាស់ផ្ទះ។

# ផ្នែកទី២ ការបង្កើត និងផ្ដាច់ទំនាក់ទំនងកុងស៊ុល

- សញ្ញាណទូទៅ

សម្រាប់ស្ថានទូត នៃទំនាក់ទំនងការទូតវិញ គឺខុសពីស្ថានកុងស៊ុល នៃទំនាក់ទំនងកុងស៊ុល គឺអាចមានតែមួយកន្លែងគត់នៅលើទឹកដីនៃរដ្ឋម្ចាស់ផ្ទះ ហើយប្រមុខការទូតមានសមត្ថកិច្ចនៅលើទឹកដីនៃរដ្ឋម្ចាស់ផ្ទះទាំងមូល។

# ផ្នែកទី២ ការបង្កើត និងផ្តាច់ទំនាក់ទំនងកុងស៊ុល

• សញ្ញាណទូទៅ

ចំណែកឯនៅក្នុងទំនាក់ទំនងកុងស៊ុលវិញ ប្រធាន ឬ ប្រមុខនៃស្ថានកុងស៊ុល មានសមត្ថកិច្ចទៅតាមដែនដីដែលបានកំណត់ទៅតាមកិច្ចព្រមព្រៀង ដែលបានធ្វើរវាងរដ្ឋដាក់កុងស៊ុល និងរដ្ឋម្ចាស់ផ្ទះ។

# ផ្នែកទី២ ការបង្កើត និងផ្ដាច់ទំនាក់ទំនងកុងស៊ុល

- បុគ្គលិកកុងស៊ុល

សូមបញ្ជាក់ថា បុគ្គលិកកុងស៊ុល (មន្ត្រីកុងស៊ុល) មានចំនួនពីរប្រភេទ ដែលក្នុងនោះរួមមាន បុគ្គលិកកុងស៊ុលដែលមានសញ្ជាតិរបស់រដ្ឋដែលដាក់កុងស៊ុល និងបុគ្គលិកកុងស៊ុលកិត្តិយស។

# ផ្នែកទី២ ការបង្កើត និងផ្ដាច់ទំនាក់ទំនងកុងស៊ុល

- បុគ្គលិកកុងស៊ុល

មន្ត្រីកុងស៊ុល គឺជាមន្ត្រីរាជ្យការរបស់រដ្ឋដែលដាក់កុងស៊ុលនោះ។ រដ្ឋដាក់កុងស៊ុលរៀបចំជ្រើសតាំងមន្ត្រីកុងស៊ុលរបស់ខ្លួនតាមរយៈឯកសារមួយដែលគេហៅថា លិខិតឪកាសទាន។

# ផ្នែកទី២ ការបង្កើត និងផ្ដាច់ទំនាក់ទំនងកុងស៊ុល

- បុគ្គលិកកុងស៊ុល

សម្រាប់បុគ្គលិកកុងស៊ុលកិត្តិយស ជាទូទៅគាត់គឺជាអាណិកជនរបស់រដ្ឋម្ចាស់ផ្ទះ។ មន្ត្រីកុងស៊ុលកិត្តិយសបំពេញការងារឲ្យស្ថានកុងស៊ុល ក្នុងក្របខណ្ឌជាអ្នកប្រកបវិជ្ជាជីវៈ ហើយពួកគេមិនទទួលបាននូវអភ័យឯកសិទ្ធិទេ។

# ផ្នែកទី២ ការបង្កើត និងផ្តាច់ទំនាក់ទំនងកុងស៊ុល

- បុគ្គលិកកុងស៊ុល

បុគ្គលិកកុងស៊ុល ក្រោយពេលដែលខ្លួនបានទទួលនូវលិខិតឪកាសទាន នោះគាត់ត្រូវបានអនុញ្ញាតឲ្យទៅបំពេញនូវមុខងាររបស់ខ្លួន នៅលើទឹកដីរបស់រដ្ឋម្ចាស់ផ្ទះ តំណាងឲ្យរដ្ឋដាក់កុងស៊ុល។

# ផ្នែកទី២ ការបង្កើត និងផ្តាច់ទំនាក់ទំនងកុងស៊ុល

- បុគ្គលិកកុងស៊ុល

លិខិតឪកាសទាន វាជាឯកសារផ្លូវការសម្រាប់បញ្ជាក់ពីការជ្រើសតាំងបុគ្គលណាម្នាក់ ហើយលិខិតនេះចេញទៅឲ្យបុគ្គលិកកុងស៊ុលនោះ ដោយរដ្ឋដាក់កុងស៊ុល ហើយលិខិតឪកាសទាននេះត្រូវបញ្ជូនទៅឲ្យរដ្ឋាភិបាលនៃរដ្ឋម្ចាស់ផ្ទះ។

# ផ្នែកទី២ ការបង្កើត និងផ្ដាច់ទំនាក់ទំនងកុងស៊ុល

- បុគ្គលិកកុងស៊ុល

ការបញ្ជូនលិខិតឪកាសទាននេះ ទៅឲ្យរដ្ឋាភិបាលនៃរដ្ឋម្ចាស់ផ្ទះ ដើម្បីអាចឲ្យកុងស៊ុលនោះចេញទៅបំពេញមុខងាររបស់ខ្លួនបាន នៅលើទឹកដីរបស់រដ្ឋម្ចាស់ផ្ទះជាផ្លូវការ គេក៏អាចនិយាយបានថា គាត់ទទួលបានលិខិតឪកាសទាន។

# ផ្នែកទី២ ការបង្កើត និងផ្តាច់ទំនាក់ទំនងកុងស៊ុល

- តួនាទីរបស់កុងស៊ុល

ដូចដែលបានបញ្ជាក់នៅក្នុងផ្នែកទី១ សេចក្តីផ្តើមនៃមេរៀននេះ មន្ត្រីកុងស៊ុល គឺបំពេញមុខងារផ្នែករដ្ឋបាលសុទ្ធសាធ ហើយគាត់មិនបំពេញមុខងារផ្នែកនយោបាយ នោះឡើយ និយាយដោយខ្លី គាត់ជាមន្ត្រីទទួលខុសត្រូវផ្នែករដ្ឋបាល។

# ផ្នែកទី២ ការបង្កើត និងផ្តាច់ទំនាក់ទំនងកុងស៊ុល

- តួនាទីរបស់កុងស៊ុល

អនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងកុងស៊ុល ឆ្នាំ ១៩៦៣ បានបញ្ញត្តិអំពីមុខងាររបស់មន្ត្រីកុងស៊ុល ហើយដូចគ្នាទៅនឹងមុខងាររបស់ភ្នាក់ងារការទូត នៃទំនាក់ទំនាងការទូតដែរ គឺមុខងារនេះ ពុំមានការកម្រិតកំណត់ទេ។

# ផ្នែកទី២ ការបង្កើត និងផ្តាច់ទំនាក់ទំនងកុងស៊ុល

- តួនាទីរបស់កុងស៊ុល

មន្ត្រីកុងស៊ុលមានតួនាទី រួមមានដូចជា៖

១. ការពារនូវផលប្រយោជន៍របស់រដ្ឋដាក់កុងស៊ុល និងអាណិកជនរបស់រដ្ឋដាក់ក្នុងស៊ុល លើទឹកដីនៃរដ្ឋម្ចាស់ផ្ទះ

# ផ្នែកទី២ ការបង្កើត និងផ្ដាច់ទំនាក់ទំនងកុងស៊ុល

- តួនាទីរបស់កុងស៊ុល

មន្ត្រីកុងស៊ុលមានតួនាទី រួមមានដូចជា៖

២. ធានាមុខងារក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន ដល់ប្រជា ពលរដ្ឋរបស់រដ្ឋដាក់កុងស៊ុល នៅលើទឹកដីនៃរដ្ឋម្ចាស់ផ្ទះ

៣. បំពេញមុខងារជាជំនួយការឲ្យតុលាការ

# ផ្នែកទី២ ការបង្កើត និងផ្តាច់ទំនាក់ទំនងកុងស៊ុល

- តួនាទីរបស់កុងស៊ុល

មន្ត្រីកុងស៊ុលមានតួនាទី រួមមានដូចជា៖

៤. បំពេញមុខងារក្នុងការចេញនូវលិខិតឆ្លងដែន ជូនពលរដ្ឋរបស់ខ្លួនដែលរស់នៅទឹកដីរបស់រដ្ឋម្ចាស់ផ្ទះ

៥. បំពេញមុខងារក្នុងចេញទិដ្ឋាការ

# ផ្នែកទី២ ការបង្កើត និងផ្តាច់ទំនាក់ទំនងកុងស៊ុល

- តួនាទីរបស់កុងស៊ុល

មន្ត្រីកុងស៊ុលមានតួនាទី រួមមានដូចជា៖

៦. សម្របសម្រួលទំនាក់ទំនងរវាងរដ្ឋដាក់កុងស៊ុល និងរដ្ឋម្ចាស់ផ្ទះ

៧. ត្រួតពិនិត្យ និងផ្តល់ជំនួយដល់នាវា យន្តហោះរបស់រដ្ឋដាក់កុងស៊ុល ជាអាទិ៍។

# ផ្នែកទី៣ អភ័យឯកសិទ្ធិកុងស៊ុល

- សញ្ញាណទូទៅ

មិនខុសគ្នាពី ភ្នាក់ងារការទូតឡើយ ដើម្បីអនុវត្តនូវមុខងារ និងតួនាទីរបស់ខ្លួនដោយឯករាជ្យ នោះមន្ត្រីកុងស៊ុលក៏ត្រូវឲ្យមានការធានានូវសុវត្ថិភាពរបស់ខ្លួន ក៏ដូចជាក្រុមគ្រួសារ ពីសំណាក់រដ្ឋម្ចាស់ផ្ទះ។

# ផ្នែកទី៣ អភ័យឯកសិទ្ធិកុងស៊ុល

- សញ្ញាណទូទៅ

ដើម្បីធានាបាននូវទំនាក់ទំនងល្អរវាងរដ្ឋដាក់កុងស៊ុល និងរដ្ឋម្ចាស់ផ្ទះ គឺត្រូវមានការធានាថា គ្មានការបំពារបំពាន ទោះជាស្ថានកុងស៊ុលរបស់រដ្ឋដាក់កុងស៊ុល ពីសំណាក់រដ្ឋដែលជាម្ចាស់ផ្ទះ ។

# ផ្នែកទី៣ អភ័យឯកសិទ្ធិកុងស៊ុល

- ខ្លឹមសារនៃអភ័យឯកសិទ្ធិកុងស៊ុល

ខុសគ្នាពីអភ័យឯកសិទ្ធិការទូត សម្រាប់អភ័យឯកសិទ្ធិកុងស៊ុលផ្ដោតសំខាន់តែទៅលើមុខងារសុទ្ធសាធ នេះមានន័យថា អភ័យឯកសិទ្ធិសម្រាប់កុងស៊ុលត្រូវបានអនុវត្តតែទៅលើកិច្ចដែលគាត់ត្រូវបំពេញក្នុងមុខងារប៉ុណ្ណោះ។

# ផ្នែកទី៣ អភ័យឯកសិទ្ធិកុងស៊ុល

• ខ្លឹមសារនៃអភ័យឯកសិទ្ធិកុងស៊ុល

ការមិនរំលោភបំពានលើស្ថានកុងស៊ុល (អគារ) និងទំនាក់ទំនងខាងផ្នែកទូរគមនាគមន៍ គឺពុំមានលក្ខណៈដាច់ខាតដូចដែលបានអនុវត្ត ចំពោះអភ័យឯកសិទ្ធិការទូតទេ។ អភ័យឯកសិទ្ធិកុងស៊ុល ទទួលបាននៅពេលបំពេញតួនាទីតែប៉ុណ្ណោះ។

មេរៀនទី១៥ ស្តីពីទំនាក់ទំនងកុងស៊ុល ត្រូវបានបញ្ចប់។ សូមអរគុណ សម្រាប់ការតាមដានដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។